# មេរៀនទី ២៣៖ លីឌាប្រែចិត្តទទួលជឿព្រះ

## កិច្ចការ ១៦៖៩-១៥

**មេរៀនសម្រាប់កុមារ** ( *យូធូបលីង* )៖ https://youtu.be/aConvKNx5KQ

**រឿងនៅក្នុងព្រះគម្ពីរសម្រាប់កុមារ៖** https://youtu.be/Vk9Y34b2O40

**គោលបំណង៖** ព្រះធ្វើការនៅក្នុងចិត្តរបស់យើង

**ខគម្ពីរចងចាំ៖ អេភេសូ ២៖១០** *"ដ្បិតយើងរាល់គ្នាជាស្នាដៃ ដែលទ្រង់បង្កើតក្នុងព្រះគ្រីស្ទយេស៊ូវ សម្រាប់ការល្អ ដែលព្រះបានរៀបចំជាមុន ឲ្យយើងរាល់គ្នាប្រព្រឹត្តតាម។"*

**ចំរៀង** ( *យូធូបលីង* )៖

១. ខ្ញុំចង់ស្គាល់ព្រះគ្រីស្ទ https://youtu.be/oM_I89dK7hs

២. ព្រះយេស៊ូវគឺជាព្រះអម្ចាស់ https://youtu.be/I-PzUIJ0MVo

៣. ខ្ញុំចូលតាមទ្វាព្រះអង្គ https://youtu.be/WvXL4DtBMdc

**១. អធិស្ឋាន**

**២. ចំរៀង** ( *រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស* )

**៣.ល្បែងកំសាន្ត** **«តើអ្នកឈ្មោះអ្វី?»**

សម្ភារៈមានកន្ទេល ឬ ភួយ

១.យើងបែងចែកកុមារជា២ក្រុមឲ្យស្មើគ្នា បន្ទាប់មកយើងឲ្យកុមារទាំង២ក្រុមគាត់ដើរសួរឈ្មោះគ្នាទៅវិញទៅមកសិន។



២.ឲ្យកុមារឈរជាជួរទល់មុខគ្នា បន្ទាប់មកគ្រូកុមារនិងគ្រូជំនួយយកកន្ទេលដាក់នៅចំកណ្តាល ដើម្បីបាំងកុំឲ្យកុមារមើលគ្នាឃើញ។

៣. ជ្រើសរើសកុមារតំណាងក្រុមម្នាក់ឲ្យឈរនៅខាងមុខគេនៅពេលគ្រូកុមាររាប់ ១ ២ ៣ គ្រូកុមារទំលាក់កន្ទេលចុះ ហើយកុមារទាំង២ដែលឈរទល់មុខគ្នាក្នុងក្រុមទាំងសងខាងត្រូវ ហៅឈ្មោះកុមារដែលយើង ឃើញនោះឲ្យបានលឿនអ្នកដែលហៅ ឈ្មោះបានលឿនជាងគេ ហើយត្រឹមត្រូវ ក្រុមរបស់គាត់នឹងទទួល បាន ១ ពិន្ទុ ត្រូវឲ្យកុមារលេងឲ្យបានគ្រប់គ្នា (កុមារម្នាក់ មានសិទ្ធិលេងបានតែម្តងតែប៉ុណ្ណោះ)។

៤. យើងបូកសរុបពិន្ទុ ក្រុមណាបានពិន្ទុច្រើនជាងគឺជាអ្នកឈ្នះ។

៥.ល្បែងកំសាន្តនេះចង់បង្ហាញកុមារថា ដើម្បីឈ្នះប្អូនៗត្រូវត្រៀមខ្លួននិយាយ ឈ្មោះដៃគូរបស់ប្អូន។ ការត្រៀមខ្លួនដើម្បីធ្វើពន្ធកិច្ចព្រះគឺជារឿងសំខាន់។

**៤. ការណែនាំមេរៀន**

មុនពេលប្រលងនៅសាលាតើប្អូនត្រៀមខ្លួនដូចម្តេចខ្លះ? (សូមឲ្យកុមារជាអ្នកឆ្លើយ- ខំរៀន, អានសៀវភៅ,ទន្ទេញមេរៀនជាដើម)។ ចុះតើប្អូនត្រូវធ្វើអ្វីខ្លះមុនពេលដែលប្អូនត្រូវចូលរួមប្រកួតបាល់ទាត់ ឬ ប្រកួត

កីឡាផ្សេងៗ? (សូមឲ្យសិស្សឆ្លើយ-ហាត់ឲ្យបានច្រើន) តើប្អូនបានទទួលជឿព្រះយេស៊ូវហើយឬនៅ? តើប្អូនជឿនៅពេលណា?ហើយតាមរយៈអ្នកណា?នៅពេលដែលប្អូនឮពាក្យថាព្រះធ្វើការនៅក្នុងចិត្តរបស់យើង តើប្អូនយល់យ៉ាងណាដែរ? (ព្រះទ្រង់បានរៀបចំចិត្តរបស់យើងជាស្រេចសម្រាប់ទ្រង់, ហើយព្រះអង្គបានជួយយើងឲ្យចេះស្តាប់បង្គាប់ទ្រង់)។

នៅថ្ងៃនេះ យើងនឹងរៀនជាមួយគ្នាអំពីស្ត្រីម្នាក់ ដែលបានត្រៀមចិត្តរួចស្រេច ដើម្បីនឹងទទួលជឿព្រះយេស៊ូវ និងទទួលយកនូវព្រះបន្ទូល ហើយស្តាប់តាមព្រះជាម្ចាស់!

## ៥. រឿងនៅក្នុងព្រះគម្ពីរ

នាយប់មួយគឺជាពេលដែលបុរសម្នាក់ឈ្មោះ ប៉ុលបាននិមិត្តឃើញរឿងមួយ ដែលវាដូចជាការយល់សប្តិអ៊ីចឹង។ ក្នុងនិមិត្តនោះ គឺឃើញបុរសម្នាក់កំពុងអង្វរប៉ុលឲ្យមកប្រទេសរបស់គាត់ដើម្បីជួយគាត់។ ប៉ុលបានដឹងច្បាស់ក្នុងចិត្តថា គឺជាព្រះជាម្ចាស់ដែលបានប្រាប់គាត់ឲ្យទៅទីនោះជាកន្លែង ដែលប៉ុល និងមិត្តរបស់គាត់ធ្លាប់ទៅពីមុន។ ពួកគាត់ចង់ប្រាប់ប្រជាជននៅទីនោះអំពីព្រះយេស៊ូវ។ នៅពេលដែលពួកគាត់ទៅដល់ទីក្រុងភីលីព ពួកគាត់ទាំងពីរបានដើរចុះទៅខាងមាត់ទន្លេ ដោយសង្ឃឹមថានឹងបានជួប មនុស្សដែលគាត់ចង់ជួប។ ពួកគាត់ទាំងពីរបានចាប់ផ្តើមនិយាយជាមួយនឹងមនុស្សមួយចំនួននៅទីនោះ ហើយមនុស្សទាំងនោះបានស្តាប់នូវអ្វីដែលលោកប៉ុល និងមិត្តរបស់គាត់និយាយយ៉ាងយកចិត្តទុកដាក់។

នៅក្នុងពេលនោះក៏ មានស្ត្រីម្នាក់ឈ្មោះ លីឌា ។ នៅក្នុងព្រះគម្ពីរបាននិយាយថា ព្រះអង្គបានបើកចិត្តរបស់គាត់ឲ្យទទួលយកនូវពាក្យដែលប៉ុល បាននិយាយអំពីព្រះយេស៊ូវ។ នេះគឺមានន័យថា ព្រះជាម្ចាស់បានជួយលីឌាឲ្យយល់ពីព្រះបន្ទូលកាន់តែច្បាស់។ រហូតធ្វើឲ្យនាង និងមនុស្សជាច្រើន ដែលនៅក្នុងផ្ទះរបស់នាងបានទទួលជឿព្រះយេស៊ូវ និងទទួលជ្រមុជទឹកផងដែរ។ លីឌា គឺជាស្ត្រីម្នាក់ដែលស្រឡាញ់ព្រះអស់ពីចិត្តរបស់នាង។ ព្រះអង្គបានរៀបចំចិត្តរបស់លីឌា! ហើយនាងបានស្តាប់តាម និងទទួលជឿទ្រង់។

លុះក្រោយមកទៀត លីឌាបានអញ្ជើញលោកប៉ុល និង មិត្តរបស់គាត់ទៅកាន់ផ្ទះរបស់នាង ហើយបានអញ្ជើញពួកគេញ៉ាំអាហារយ៉ាងឆ្ងាញ់ទៀតផង។ ព្រះអង្គស្រឡាញ់លីឌាខ្លាំងណាស់ ទើបបានជាទ្រង់បានចាត់ឲ្យលោកប៉ុលទៅកាន់ក្រុងភីលីព។ ទ្រង់បានរៀបចំអ្វីគ្រប់យ៉ាងសម្រាប់នាង ដូច្នេះហើយទើបធ្វើឲ្យនាងអាចឮពីព្រះយេស៊ូវបាន។ នាងបានត្រៀមដួងចិត្តរបស់នាងរួចជាស្រេចសម្រាប់ទ្រង់។

ព្រះអង្គក៏បានធ្វើដូច្នេះចំពោះយើងផងដែរ ដោយទ្រង់បានឲ្យយើងត្រៀមរួចជាស្រេច ដើម្បីរៀនពីទ្រង់បន្ថែមទៀត។ ព្រះអង្គធ្វើការនៅក្នុងចិត្តរបស់យើង ដើម្បីឲ្យយើងអាចធ្វើនូវអ្វីដែលទ្រង់បានបង្កើតឲ្យយើងធ្វើ យើងអាចឮពីព្រះបន្ទូលរបស់ទ្រង់ ហើយយើងនឹងអាចស្រឡាញ់ និងបម្រើទ្រង់ទៅតាមផ្លូវដែលព្រះអង្គបានរៀបចំសម្រាប់យើង។ សូមឲ្យយើងបានអរព្រះគុណចំពោះទ្រង់ ដែលព្រះអង្គធ្វើការនៅក្នុងចិត្តរបស់យើង!

## ៦. សំនួរពិភាក្សា

១. តើស្ត្រីដែលបានស្រឡាញ់ព្រះអស់ពីចិត្តរបស់នាងមានឈ្មោះអ្វី? *(លីឌា)*

២. បន្ទាប់ពីទទួលជឿនូវព្រះបន្ទូលដែលនិយាយពីព្រះយេស៊ូវតើកិច្ចការ ២យ៉ាងដែលនាងបានធ្វើគឺអ្វីខ្លះ?

*(នាងទទួលជ្រមុជទឹក និង បានអញ្ជើញលោកប៉ុល និង មិត្តរបស់គាត់ទៅញុំាអាហារយ៉ាងឆ្ងាញ់នៅផ្ទះរបស់នាង)*
៣. តើព្រះអង្គបានប្រើប្រាស់វិធីអ្វីខ្លះដើម្បីធ្វើការនៅក្នុងចិត្តរបស់យើងសម្រាប់ទ្រង់?
*(ព្រះបន្ទូលនៅក្នុងគម្ពីរ, ការអធិស្ឋាន,ស្ថានភាពផ្សេងៗ,មនុស្សដែលនៅជុំវិញយើង។ល។)*

**៧. ល្បែងកំសាន្ត «តើអ្នកបានត្រៀមខ្លួនរួចឬនៅ?»**

សម្ភារៈដែលត្រូវការៈ ក្រដាស និងខ្មៅដៃមួយចំនួនសម្រាប់ចែកឲ្យក្រុមនីមួយៗ, រង្វាន់លើកទឹកចិត្ត (ស្ករគ្រាប់)




១. ចែកកុមារជាក្រុមដែលមានគ្នាពី ៣ ឬ ៤ នាក់ ដើម្បីធ្វើការប្រកួតប្រជែងគ្នា។
២.ក្នុងក្រុមនីមួយៗត្រូវជ្រើសរើសនរណាម្នាក់ដែលអាចរត់បានលឿនជាងគេ ដើម្បីរត់ពីទីដែលបាន កំណត់ចាប់ផ្តើម រហូតទៅដល់ចុងម្ខាងនៃថ្នាក់រៀន រួចរត់ត្រលប់មកកន្លែងដើមវិញ។
៣. **ប៉ុន្តែ** មុនពេលដែលពួកគេចាប់ផ្តើមរត់ ពួកគេត្រូវតែជួយគ្នាឆ្លើយនូវសំណួរជាក្រុមសិន
៤.គ្រូសូមពន្យល់កុមារថា មានវិធីជាច្រើនដែលយើងត្រូវធ្វើ ដើម្បីឲ្យចិត្តរបស់យើងអាចត្រៀមរួចជាស្រេចដើម្បីជឿ និងដើរតាមព្រះ។ ក្រុមណាដែលអាចសរសេរនូវវិធី ៣យ៉ាង ដែលជួយឲ្យយើងត្រៀមចិត្តរួចជាស្រេច ហើយយកឲ្យគ្រូពិនិត្យមើល គឺជាក្រុមដែលត្រូវចាប់ផ្តើមរត់ប្រណាំងបាន។
៥. សូមឲ្យជារង្វាន់លើកទឹកចិត្តដល់ក្រុមដែលឈ្នះក្នុងការប្រកួត

**៨. ខគម្ពីរចងចាំ**

**អេភេសូ ២៖១០** *"ដ្បិតយើងរាល់គ្នាជាស្នាដៃ ដែលទ្រង់បង្កើត ក្នុងព្រះគ្រីស្ទយេស៊ូវ សម្រាប់ការល្អ ដែលព្រះបានរៀបចំជាមុន ឲ្យយើងរាល់គ្នាប្រព្រឹត្តតាម"។*

**៩. ហាត្ថកម្ម « សូមអរគុណ »**

សម្ភារៈដែលត្រូវការៈ ផ្កាយ (សូមបោះពុម្ពរូបផ្កាយនៅទំព័រខាងក្រោម), ឈើការ៉េម




១.ដូចដែលលីឌាបានធ្វើ ដើម្បីជាការថ្លែងអំណរគុណចំពោះប៉ុល និងមិត្តភក្តិរបស់គាត់ ពួកយើងក៏នឹងធ្វើនូវកាដូពិសេសមួយ ជូនចំពោះមនុស្សដែលយើងស្រឡាញ់ផងដែរ។
២.សូមជួយកុមារធ្វើឈើវេទមន្តចំនួនពីរ ឈើមួយសម្រាប់ខ្លួនឯង ហើយមួយទៀតគឺ សម្រាប់ជូនទៅមនុស្ស ដែលគេស្រឡាញ់។



៣.ឲ្យកុមាររចនានូវរូបផ្កាយ រួចកាត់ជារាងផ្កាយ ហើយយកទៅបិតនៅលើបន្ទះ ឈើកាវ៉េម។
៤.នៅពេលដែលឈើវេទមន្តរបស់ពួកគេរួចរាល់ហើយ សូមជួយឲ្យសិស្សហាត់និយាយនូវឃ្លាមួយចំនួន នៅពេលដែលពួកគេឲ្យឈើវេទមន្តរបស់ពួកគេទៅកាន់មនុស្សដែលគេស្រឡាញ់។ អាចជា "ព្រះយេស៊ូវ ស្រឡាញ់អ្នក, ហើយខ្ញុំក៏ស្រឡាញ់ អ្នកដែរ" ឬក៏ "ខ្ញុំសូមអរគុណដែលឯងធ្វើជាមិត្តរបស់ខ្ញុំ" ។

**១០. ចំរៀង** *(រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស)*

## ១១. អធិស្ឋាន

**ការថ្វាយបង្គំសំរាប់គ្រួ៖** ( **សូមអាន ហើយអធិស្ឋានមុនពេលចាប់ផ្តើមបង្រៀន** )
នៅពេលដែលអ្នកចំណាយពេលកាន់តែច្រើនជាមួយនឹងនរណាម្នាក់ វាធ្វើឲ្យអ្នកកាន់តែមានភាពជិតស្និទ្ធិជាមួយនឹងអ្នកនោះកាន់តែខ្លាំង។ លោកប៉ុលបានចំណាយពេលវេលាជាច្រើនជាមួយនឹង ព្រះជា-ម្ចាស់ក្នុងគោលបំណង ដើម្បីស្វែងយល់ពីព្រះហឫទ័យរបស់ព្រះសម្រាប់គាត់។ ដូចដែលអ្នកចំណាយពេលជាមួយនឹងព្រះយេស៊ូវតាមរយៈការសិក្សានូវព្រះបន្ទូល និង អធិស្ឋានផងដែរ សូមព្យាយាមស្វែងយល់ពីបំណងព្រះហឫទ័យរបស់ព្រះចំពោះអ្នក និងព្យាយាមធ្វើតាមបំណងព្រះហឫទ័យរបស់ទ្រង់។ បំណងព្រះហឫទ័យដ៏សំខាន់បំផុតរបស់ព្រះ គឺទ្រង់ចង់ឲ្យមនុស្សគ្រប់គ្នាបានស្គាល់ពីព្រះគ្រីស្ទ។ នៅក្នុងសប្តាហ៍នេះ សូមស្វែងរកមនុស្សម្នាក់ ដើម្បីចែករំលែកនូវសេចក្តីស្រឡាញ់របស់ព្រះជាមួយនឹងគេ។

